# រដ្ឋ Panchayati Raj (២០០៧-២០០៨)

## សវនកម្មសង្គម

– Binoy Acharya **និង** Arun Kumar[១]

ជាច្រើនឆ្នាំកន្លងមក គឺមានការរីកសាយផ្នែកគ្រឹះស្ថានស្វយ័ត។ ការរីកសាយនេះបណ្តាលឱ្យមានការចែករំលែកនូវជំនឿទុកចិត្តលើផ្នែកសង្គម និងសេដ្ឋកិច្ចរវាងពួកគេ។ សវនកម្មធ្វើការចរចា និងធ្វើបទបង្ហាញអំពីការជឿជាក់ និងការគ្រប់គ្រងរវាងគ្រឹះស្ថានទាំងនេះ (អំពីអំណាច ឆ្នាំ១៩៩៧)។ សវនកម្មត្រូវបានគេប្រើប្រាស់ជាដំបូងក្នុងការត្រួតពិនិត្យមើលលើកិច្ចការជំនួញជាច្រើន ប៉ុន្តែដោយសារតែទំហំ និងការរីកសាយភាយកើនឡើងនោះចំណុចផ្តោតបានប្តូរទៅវាស់វែងលើកម្លាំងនៃប្រព័ន្ធគ្រប់គ្រងវិញ។ ទាំងនេះគឺមាននៅក្នុងតម្លៃនៃការត្រួតពិនិត្យដែលសំដៅដល់ការស្វែងរកភាពដែលមិនស្របគ្នាហើយនិងកំហុសឆ្គងនានា។ ដោយមានការកើនឡើងជាលំដាប់ សវនកម្មបានកែលម្អលើវិស័យហិរញ្ញវត្ថុ ហើយដែលពេលនេះ គឺកំពុងត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការបង្កើនការដំណើរការរៀបចំចាត់ចែង និងការផ្ទេរការងារគ្រប់គ្រង (ក្នុងសៀវភៅដដែល)។

នៅក្នុងគ្រឹះស្ថានអភិបាលកិច្ច មានការផ្លាស់ប្តូរចំនួនបី ដែលត្រូវបានគេកត់សម្គាល់ (១) ការផ្លាស់ប្តូរលើបែបបទនៃបទបញ្ញត្តិដែលប្តូរពីការហាមឃាត់ទៅជាការអនុលោមតាមវិញ (២) គំនិតផ្តើមដែលកើនឡើងនៅក្នុងគុណភាពក្នុងការគ្រប់គ្រង ហើយ (៣) ការអនុវត្តគោលការណ៍ឯកជនសម្រាប់កំណែទម្រង់វិស័យសាធារណៈ។ ស្ថិតនៅក្រោមការគ្រប់គ្រងសាធារណៈបែបថ្មី មានការធ្លាក់ចុះជាលំដាប់ក្នុងការចែកចាយសេវាកម្មរបស់រដ្ឋ។ ការធ្លាក់ចុះនេះបានបណ្តាលឱ្យមានការបែងចែកគ្រឹះស្ថានអភិបាលកិច្ច ហើយនិងការផ្តល់នូវសេវាកម្ម។ នៅក្នុងករណីបែបនេះការត្រួតពិនិត្យនៃយុទ្ធសាស្ត្ររវាងភ្នាក់ងារគ្រប់គ្រង និងចែកចាយត្រូវបានបង្កើតឡើងតាមរយៈអ្នកកំណត់គោលនយោបាយសវនកម្ម ការវាយតម្លៃ ហើយនិងការត្រួតពិនិត្យ ( Neave ឆ្នាំ ១៩៨៨) ដូច្នេះការិយាធិបតេយ្យ ត្រូវបានជំនួសដោយច្បាប់គ្រប់គ្រងសវនកម្ម និងគណនេយ្យវិញ ( Self ១៩៩៣)។ ការពិត សវនកម្ម និង គណនេយ្យត្រូវបានស្គាល់ថាជា អព្យាក្រិត្យដែលរីកសាយភាយ និងមានប្រសិទ្ធភាព (Hood ឆ្នាំ ១៩៩១) ដែលបានជួយឱ្យវាទទួលបានរូបិយប័ណ្ណដែលគេទទួលស្គាល់។

សវនកម្មនាពេលថ្មីៗនេះកំពុងត្រូវបានប្រើប្រាស់ដើម្បីធានា (១) ដោយអនុលោមតាមផ្នែកខុសៗគ្នានានា រួមមានអ្នកដែលនៅក្នុងការគ្រប់គ្រងសម្រាប់គ្រឹះស្ថាន (២) ត្រួតពិនិត្យតាមដាន និងដាក់បទបញ្ញត្តិលើទំនាក់ទំនង។ (៣) វាយ

---

[1] Binoy Acharya និង Arun Kumar ធ្វើការជាមួយ UNNATI – អង្គការសម្រាប់ការអភិវឌ្ឍវិស័យអប់រំ ដែលបានធ្វើការទៅលើការគ្រប់គ្រងបែបវិមជ្ឈការអស់រយៈពេលជាង ១២ឆ្នាំ ជាពិសេសនៅក្នុង Rajasthan និង Gujarat។

តម្លៃទៅលើការអនុវត្ត និងសេចក្តីពេញចិត្តរបស់អ្នកប្រើប្រាស់ និង (៤) វិធានការសម្រាប់កំណែទម្រង់លើកដំបូង ដូចជាការផ្តល់ជូនសេវា សុខភាព និងការអប់រំ។ តម្រូវការក៏កំពុងត្រូវបានកើនឡើងផងដែរ សម្រាប់មុខសញ្ញាកំណត់នៅក្នុងការធ្វើសវនកម្ម។ នេះគឺជាការខ្វល់ខ្វាយចំពោះការកំណត់ទៅលើ "មូលហេតុ" (Friedman ១៩៩១)។ ប៉ុន្តែសវនកម្មត្រូវបានគេរិះគន់ទៅលើការអស់សង្ឃឹមនៅក្នុងឱកាសនៃគណនេយ្យភាព (Day និង Klein ១៩៩១)។ ពួកគេមិនសំដៅទៅដល់ការបង្ក ឬ ស្នើសុំឱ្យមានការពិភាក្សាទេ (អំពីអំណាច នៅក្នុងសៀវភៅដដែល)។ Day និង Klein (១៩៩១) ពិភាក្សាឆ្លើយតបទៅនឹងតម្រូវការចំពោះ " ការភ្ជាប់បន្ថែមនៅក្នុងការពិភាក្សានៃពលរដ្ឋ ដើម្បីបង្កើតឱ្យមានយ៉ាងហោចណាស់អ្វីមួយនៃភាពដែលអាចមើលឃើញ និងភាពផ្ទាល់នៃគណនេយ្យភាពដែលនៅចំពោះមុខ"។

ជាមួយអ្វីដែលបានលើកឡើងខាងលើ សវនកម្មសង្គមត្រូវបានណែនាំទៅកាន់ការពិភាក្សា និងការពិនិត្យពិច័យជាសាធារណៈលើកដំបូង។ ពួកគេអាចជួយស្វែងរកអ្វីដែលពាក់ព័ន្ធទៅនឹងគោលបំណង ហើយនិងដំណើរការដែលបានចូលរួមនៅក្នុងនោះ។ ជាពិសេសនៅក្នុងបរិបទតាមតំបន់ សវនកម្មសង្គមមួយចំនួនជួយក្នុងការស្រាវជ្រាវរកអ្វីដែលពាក់ព័ន្ធ ហើយផលចំណេញនៃការចំណាយ។ សក្តានុពលរបស់ពួកគេគឺការស្រាវជ្រាវរក "មូលហេតុ" ហើយនិងបង្កើតឱ្យមានដំណោះស្រាយនៅតាមតំបន់ ដែលមិនអាចផ្តោតទៅលើ[២] ។ វាអាចផ្តល់ជូនក្នុងការស្នើឱ្យមានកិច្ចពិភាក្សាជាសាធារណៈក្នុងការគៀងគរសម្រាប់ការតភ្ជាប់នៃប្រជាពលរដ្ឋ ការបង្កើតឱ្យមានដំណោះស្រាយទ្រង់ទ្រាយតូច ឬ ក្នុងរូបភាពជាការត្រួតពិនិត្យ និងការថ្លឹងថ្លែងលើវិធានការនៅថ្នាក់មូលដ្ឋាន។ ការយល់ច្បាស់ពីសវនកម្មសង្គមនៅក្នុងការបង្កើតបរិបទតាមមូលដ្ឋានអាចរួមចំណែកក្នុងការផ្លាស់ប្តូរធំៗឱ្យកាន់តែមានប្រសិទ្ធភាពឡើងតាមរយៈការណែនាំ និងការបង្កើតវិធីសាស្ត្រនៅតាមកម្រិតគោលនយោបាយ។ គេចង់បង្កើតសវនកម្មសង្គម ដើម្បីធ្វើឱ្យការចែកចាយជាសាធារណៈមានប្រសិទ្ធភាព (Aakella និង Kidambi ២០០៧)។ ដូច្នេះសវនកម្មសង្គមអាចផ្តល់ឱ្យភ្លាមៗនូវគោលបំណងនៃសវនកម្មមួយជាវិធានការសម្រាប់គណនេយ្យភាព និងសេវាកម្ម និងកំណែទម្រង់អភិបាលកិច្ច ដោយមិនចាំបាច់មានការត្រួតត្រាលើប្រព័ន្ធដែលជាដំណោះស្រាយចុងក្រោយ (Sieber, ១៩៨១) ឬ ការបង្កើតការចាំឃ្លាំមើលនៅក្នុងដំណាក់កាលនៃការធ្វើអធិការកិច្ចទេ (Day and Klein, ១៩៩0)។ ក្រៅពីផលប៉ះពាល់ផ្ទាល់របស់ពួកគេ សវនកម្មសង្គមអាចធ្វើការលើសកម្មភាព

---

[2] សម្រប់ព័តិមានបន្ថែមស្តីអំពីប្រសិទ្ធភាពនៃ សវនកម្មសង្គមក្រោមរូបភាពជា ការលើកកម្ពស់គណនេយ្យភាពសូមមើល Datta, Saikat (2008) ដែលមានចំណងជើងថា 'Slush Filter Does its Job' in *Outlook*, ចេញផ្សាយថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ពីទំព័រទី ១៦-១៨ អត្ថបទចំណងជើងថា 'Social Audit Reveals Large Scale Fraud' នៅក្នុង The Hindu ចេញផ្សាយថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០០៨ (បោះពុម្ពផ្សាយដោយ Delhi) អត្ថបទចំណងជើងថា 'Social Auditors have their Way' នៅក្នុង The Hindu ចេញផ្សាយថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ ២០០៨ (បោះពុម្ពផ្សាយដោយ Delhi) អត្ថបទចំណងជើងថា 'Janta ko chahiye paise ka hisaab' នៅក្នុង Rajasthan Patrika ចេញផ្សាយថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០០៨ (បោះពុម្ពផ្សាយដោយ Jaipur ) ។ល។

នយោបាយសមូហភាពបន្ថែមនៅតាមថ្នាក់មូលដ្ឋានតាមរយៈការកសាង និងការពង្រឹងបណ្តាញនៅក្នុង សង្គម (Bates, ១៩៩៤) ហើយនិងការចែកចាយដោយ "ភាពពេញចិត្តជារួម " (North, ១៩៩០) ។ ប៉ុន្តែមានតម្រូវការមួយសម្រាប់ការប្រែសម្រួលលើភាពច្បាស់លាស់នៃខ្លឹមសារឱ្យទៅជាការអនុវត្ត ជាពិសេសអ្វីដែលទាក់ទងទៅនឹងសមាសភាគសង្គមនៃសវនកម្មសង្គម ក្រៅពីនេះគេអាចត្រៀមសម្រាប់បញ្ឈប់ការអនុវត្តដែលបានសម្របសម្រួល ដោយមិនមានការចូលរួមចំណែកពិតប្រាកដក្នុងគោលបំណងប្រជាធិបតេយ្យបន្ថែមទៀតទេ។

## សវនកម្មសង្គមៈ គន្លឹះនៃគោលនយោបាយ និងបទបញ្ញត្តិដែលបានចែង

ការទទួលស្គាល់ចំពោះតម្រូវការសម្រាប់លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងនោះមានគណនេយ្យភាព និងតម្លាភាពនៅ Gram Panchayat សវនកម្មសង្គមត្រូវបានគេបង្កើតឡើងនៅក្នុងរដ្ឋចំនួន ៧ ក្នុងចំណោមរដ្ឋ Assam, Gujarat, Jammu និង Kashmir, Karnataka, Kerala, Rajasthan និង Sikkim និងនៅក្នុង Daman and Diu ។ រដ្ឋទាំង៧ បានចេញនូវគោលការណ៍ណែនាំលម្អិតសម្រាប់ធ្វើសវនកម្មសង្គមទាំងនេះ (ក្រសួង Panchayati Raj រដ្ឋាភិបាលឥណ្ឌា ២០០៦-០៧)។ បន្ថែមលើនេះ ដើម្បីធ្វើសវនកម្មសង្គមនៅក្នុងរដ្ឋ Assam, Jammu and Kashmir, Karnataka និង Punjab បទបញ្ញត្តិត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យលើការរីកចម្រើនដោយ Gram Sabha (ការប្រជុំតាមភូមិ)។ អំឡុងពេលដែលអ្នកនៅក្នុង Andhra Pradesh, Arunachal Pradesh ហើយនិង Uttarakhand មិនយកចិត្តទុកដាក់ចំពោះសវនកម្មសង្គមនោះទេ ប៉ុន្តែមានបទបញ្ញត្តិមួយចំនួនដើម្បីធ្វើការត្រួតពិនិត្យសារជាថ្មីលើការរីកចម្រើនដោយ Gram Sabhas ។ មានរដ្ឋតែចំនួន៦ ប៉ុណ្ណោះដែលរួមមាន Himachal Pradesh, Jammu និង Kashmir, Jharkhand, Orissa និង Sikkim បានបង្កើតបទបញ្ញត្តិជាក់លាក់មួយចំនួន នៅក្នុងនីតិកម្ម ដើម្បីជួយដល់ការចូលរួមរបស់ស្ត្រី អ្នកដែលមកពីវណ្ណៈដែលគេកំណត់ (Scheduled Castes) និងក្រុមកុលសម្ព័ន្ធ ហើយនិងពលករដែលមិនមានដីធ្លី។

វាត្រូវបានគេលើកឡើងថា Gram Sabhas ត្រូវបានគេទទួលស្គាល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការជួយពង្រឹងដល់ការធ្វើអភិបាលកិច្ចវិមជ្ឈការនៅតាមតំបន់ជនបទ ដែលត្រូវបានគេរៀបចំនៅក្នុងប្រទេស ។ ទាំងនេះ គឺជាស្ថាប័ននៃប្រជាធិបតេយ្យផ្ទាល់ (Jai Prakash Narain ដកស្រង់ពី Dr. Mahi Pal ការិយាល័យព័ត៌មានអំពីការបោះពុម្ពផ្សាយលេខ ៣៧) គឺចង់ផ្តល់ឱ្យនូវមុខងារមួយចំនួនទៅកាន់រដ្ឋទាំងនោះ ដោយនីតិកម្មអាចត្រូវបានផ្តល់ជូន។ គឺជាវេទិកាដែលអនុវត្តសិទ្ធិប្រជាធិបតេយ្យនៅតាមមូលដ្ឋាន។ ដោយមានការ រៀបចំចាត់ចែងពីរដងក្នុងមួយឆ្នាំ Gram Sabhas រៀបចំផែនការសម្រាប់ការអភិវឌ្ឍ កំណត់អត្តសញ្ញាណអ្នកដែលទទួលផលពីគម្រោង ហើយជួយសម្រួលដល់ការអនុវត្ត ព្រមទាំងផ្តល់នូវចន្លោះនីតិបញ្ញត្តិ ដែលសំណួរត្រូវបានសួរដោយប្រជាពលរដ្ឋ ហើយនិងការស្វែងរកភាពច្បាស់លាស់។ យោងទៅលើរដ្ឋ

Panchayati Raj ឆ្នាំ ២០០៦-០៧ (ក្រសួង Panchayati Raj រដ្ឋាភិបាលឥណ្ឌា) រដ្ឋទាំងអស់នៅក្នុងប្រទេសបានធ្វើនីតិកម្មលើ Gram Sabhas ដើម្បីជ្រើសរើសអ្នកដែលទទួលផល ហើយអនុម័តផែនការសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុង Gram Panchayat (ក្រុមប្រឹក្សាភូមិ)។

សវនកម្មសង្គមទទួលបាននូវមុខមាត់ដែលមានប្រជាប្រិយភាពនៅក្នុងប្រទេស ជាមួយនឹងគម្រោងធានារ៉ាប់រងការងារនៅតាមជនបទទូទាំងប្រទេស ដែលការផ្តល់ជូនប្រាក់ខែ ផែនការការងារ និងសម្ភារនៅកន្លែងធ្វើការងារត្រូវបានកំណត់ថា និងត្រូវបានគេបង្កើតឡើង និងអនុវត្តនៅតាមថ្នាក់មូលដ្ឋាន នៅក្នុងមាត្រដ្ឋានថ្នាក់ជាតិទ្រង់ទ្រាយធំជាមួយនឹង Gram Panchayat ក្នុងលក្ខណៈជាអាជ្ញាធរដែលសំខាន់ (ក្រសួងអភិវឌ្ឍជនបទ រដ្ឋាភិបាលឥណ្ឌា ឆ្នាំ២០០៥ និង UNDP ឆ្នាំ ២០០៦)។ ដោយយោងតាមក្រសួងអភិវឌ្ឍជនបទ រដ្ឋាភិបាលឥណ្ឌា (២០០៦) សវនកម្មសង្គម សិទ្ធិក្នុងការទទួលបានព័ត៌មានត្រូវបានរំពឹងថានឹងរក្សាច្បាប់សម្រាប់ការធានាតម្លាភាព និងគណនេយ្យភាព នៅតាមថ្នាក់មូលដ្ឋាន តាមរយៈ Gram Sabha ក្នុងរូបភាពជាការឃ្លាំមើលជាសាធារណៈជាបន្តបន្ទាប់ (ច្បាប់ធានាដល់ការងារតាមជនបទថ្នាក់ជាតិ រដ្ឋាភិបាលឥណ្ឌាឆ្នាំ ២០០៥)។ សវនកម្មសង្គមមានទិសដៅលើកកម្ពស់តម្លាភាព ការចូលរួម ការប្រឹក្សា និងការព្រមព្រៀង គណនេយ្យភាព ហើយនិងការកែតម្រូវបញ្ហាសាធារណៈ។ គោលការណ៍ណែនាំដែលលម្អិតត្រូវបានចេញស្ថិតក្រោម NREGS ចំពោះការប៉ះពាល់នេះដែលក្នុងនោះ (ក) ការផ្សព្វផ្សាយជាសាធារណៈ និងការរៀបចំ (ខ) ទិដ្ឋភាពរៀបចំចាត់ចែង និងនីតិវិធី និង (គ) របៀបវារៈនៃបទបញ្ហា។

## វិធីសាស្រ្តនៃសវនកម្មសង្គម

ភាពចម្រុះក្នុងបទពិសោធន៍នៃសវនកម្មសង្គមបានបណ្តាលឱ្យមានសេចក្តីថ្លែងការណ៍ជាពហុភាពទៅលើតួនាទីនៃសវនកម្មសង្គមក្នុងលក្ខណៈជាច្បាប់សម្រាប់ កែទម្រង់ និងសម្រាប់ប្រសិទ្ធភាពរបស់វា។ អំណាច (១៩៩៧) បានបង្កើតជាសំណួរថា តើការធ្វើសវនកម្មគឺសំដៅដើម្បីបង្កើតភាពចុះសម្រុង ឬ ពួកគេបង្កជាភាពខ្វែងគំនិត។ នៅចំពោះមុខភ្នាក់ងារចម្រុះសវនកម្មសង្គមបានបង្កើតជាទម្រង់បែបបទជាច្រើនដែលរាប់ចាប់ពីអ្វីដែលបង្កើតភាពចុះសម្រុង ទៅដល់ភាពខ្វែងគំនិត។ ប៉ុន្តែការវិភាគនៃការអនុវត្តសវនកម្មសង្គមបានផ្តល់ឱ្យនូវវិធីសាស្រ្តបីខុសៗពីគ្នា
បើទោះបីជាវិធីសាស្រ្តនីមួយៗមិនអាចបែងចែកពីគ្នា ឱ្យដាច់ស្រឡះ ឬ មិនចុះសម្រុងគ្នាទៅវិញទៅមកក៏ដោយ។

### *ការផ្សាយចេញជាលក្ខណៈសកម្ម*

វិធីសាស្រ្តទីមួយផ្តោតទៅលើតម្រូវការសម្រាប់ដាក់បទបញ្ជាដោយខ្លួនឯង តាមរយៈសេចក្តីថ្លែងការណ៍ជាលក្ខណៈសកម្ម ។ នៅចុងបញ្ចប់រដ្ឋាភិបាលបានកំពុងធ្វើការតាមឋានានុក្រមផ្សេងៗដូចជាសិទ្ធិទទួលបានពីសហប្រតិបត្តិការក្នុងផ្នែកនយោបាយដែលថ្លែងទៅកាន់ក្រុមតំណាងនៃមន្ត្រីផ្នែករដ្ឋបាលតាមភូមិ។

សវនកម្មសង្គមត្រូវបានធ្វើឡើងសម្រាប់វិស័យចម្រុះ ដូចជាការអប់រំនៅបឋមសិក្សាការផ្គត់ផ្គង់ទឹកសម្រាប់បរិភោគ និងសេវាថែទាំសុខភាព ចំពោះការតែងតាំង ការចូលរួម និងដំណើរការនៃមន្ត្រីរដ្ឋបាល។ ច្បាប់ជាច្រើននៃការចេញផ្សាយរបស់ Gram Panchayat ជាលក្ខណៈសកម្មរួមមាន ការចេញផ្សាយព្រឹត្តិបត្រព័ត៌មានជាទៀងទាត់នៅតាមកន្លែងធ្វើការងារ ដើម្បីផ្តល់នូវព័ត៌មានដែលចាំបាច់ បង្ហាញពីការចំណាយ និងអំពីបញ្ជីឈ្មោះអ្នកទទួលផលពីគម្រោងជាដើម។ នៅក្នុងកំណត់ហេតុអង្គប្រជុំមួយចំនួនរបស់ Gram Sabha និងព័ត៌មានដែលបង្ហាញនៅក្នុងការិយាល័យរបស់ Gram Panchayat ។ រដ្ឋ Kerala គឺជារដ្ឋដំបូងគេបង្អស់ដែលចេញផ្សាយលើកដំបូងតាមរយៈ ក្តាសម្រាប់ព្រឹត្តិប័ត្រចេញផ្សាយនានា ។ បច្ចុប្បន្ននេះមានរដ្ឋភាគច្រើនកំពុងតែអនុវត្តបែបនេះ។

## *សកម្មភាពសហការគ្នា*

វិធីសាស្ត្រទីពីរនេះគឺផ្អែកទៅលើទម្រង់នៃការសហការ ដែលផុសចេញពីចេតនាក្នុងចិត្ត ការបង្កើតភាពស្របគ្នា និងការលើកកម្ពស់គណនេយ្យភាពតាមរយៈសកម្មភាពប្រជាពលរដ្ឋ។ភ្នាក់ងារប្រជាពលរដ្ឋនៅតាមថ្នាក់មូលដ្ឋានភាគច្រើនធ្វើការងារដោយប្រឹក្សាជាមួយនឹងថ្នាក់ដឹកនាំ រួមគ្នាជាមួយការកៀងគរ និងការពិនិត្យពិច័យនៃសហគមន៍ ហើយជាចុងក្រោយចំពោះការជួយសម្រួលនៃសវនកម្មសង្គម។ វិធីសាស្ត្រនេះត្រូវបានគេយកធ្វើជាគោលសម្រាប់បង្កើតចន្លោះសម្រាប់ការពិភាក្សាតាមរយៈ ការកសាងសមត្ថភាព ការផ្តល់ឱ្យនូវបទបញ្ញត្តិនៅក្នុងគោលនយោបាយទាន់ពេលវេលា និងបរិយាកាសនៅតាមមូលដ្ឋានក្នុងលក្ខណៈជាច្បាប់ផ្សេងៗ។ គំរូនេះគឺផ្អែកទៅលើការជួយសម្រួលឱ្យទទួលបានព័ត៌មាន និងសវនកម្មសង្គម។ ប៉ុន្តែបច្ចុប្បន្ននៅក្នុងដំណាក់កាលចាប់ផ្តើមរបស់ខ្លួនវិធីសាស្ត្រនេះបានផ្តល់នូវភាព ដែលមិនអាចជឿជាក់បានជាទូទៅរវាងភ្នាក់ងាររបស់រដ្ឋាភិបាលដែលរួមមានអ្នកដែលត្រូវបានជ្រើសរើសជាមួយនឹងភ្នាក់ងារសង្គមស៊ីវិល ។ ទម្រង់នេះកំពុងតែត្រូវបានអនុវត្តដោយរដ្ឋដែលស្ថិតក្រោមការគ្រប់គ្រងរបស់NREGS ។ អង្គការសង្គមស៊ីវិលនៅក្នុងរដ្ឋជាច្រើនបើទោះបីជាត្រូវបានគេកម្រិតវិសាលភាពខ្លួនក្តី ក៏បាននឹងកំពុងធ្វើប័ណ្ណរបាយការណ៍ (អំពីភាពពេញចិត្តនៃអ្នកប្រើប្រាស់សេវាកម្មនានា) លើគម្រោងដូចជា ប្រព័ន្ធចែកចាយ ជាសាធារណៈ អាហារពេលថ្ងៃ Anganwadis (មជ្ឈមណ្ឌលថែទាំកុមារ) ជាដើម ។ នៅក្នុងការសហការជាមួយនឹង Gram Panchayats។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលជួយសម្រួលដល់ដំណើរការនេះជឿជាក់ថា នៅពេលដែលការត្រួតពិនិត្យនៃសេវាកម្មជាមូលដ្ឋានត្រូវបានធ្វើឡើងក្នុងលក្ខណៈដែលមិនមានការគំរាមកំហែងនោះ សមាជិកសហគមន៍គង់ទទួលបានទំនុកចិត្តជាសន្សឹមៗក្នុងការទាមទាររកគណនេយ្យភាព។

## ***ការប្រឆាំងនឹងអំពើពុករលួយ***

ទីបីទាក់ទងទៅនឹងវិធីសាស្ត្រនានាដើម្បីបរិយាយយ៉ាងច្បាស់លាស់ ពីសវនកម្មសង្គមថាជាល័ក្ខខ័ណ្ឌផ្លូវច្បាប់ក្នុងការប្រើប្រាស់អំណាចនៅក្នុងស្ថាប័នរដ្ឋ ។ ការកំណត់លក្ខណៈចែកដាច់សំខាន់ៗនៃវិធីសាស្ត្រនេះគឺអវត្តមាននៃភ្នាក់ងាររបស់រដ្ឋ។ វាប្រើប្រាស់នូវបទពិសោធន៍នៃភស្តុតាង របាយការណ៍ និងការត្រួតពិនិត្យដើម្បីរក្សាឱ្យបាននូវ គណនេយ្យភាព Panchayats នៅតាមថ្នាក់មូលដ្ឋាន។ វិធីសាស្ត្រនេះគឺពឹងផ្អែកលើការប្រើប្រាស់សិទ្ធិក្នុងការទទួលបានព័ត៌មាន ដើម្បីទទួលបាននូវរបាយការណ៍ជាសាធារណៈ។ វេទិកាសាធារណៈលើកដំបូងស្តីពីករណីកើតមាន នៅក្នុង Jan Sunvaai (វេទិកាជាសាធារណៈ) ដែលត្រូវបានគេប្រើធ្វើជាទីកន្លែងបើកឱកាសនិងជាច្បាប់លើការគៀងគរសហគមន៍សម្រាប់សកម្មភាពប្រជាពលរដ្ឋ ។ ដោយបានទទួលនូវព័ត៌មានដែលចាំបាច់វាត្រូវបានគេជឿជាក់ថា សវនកម្មសង្គមគួរតែតភ្ជាប់អំណាចទៅឱ្យសហគមន៍ ។ ជាការឆ្លើយតបទៅនឹងការស្ថាបនាដែលមិនសមស្របនៃសវនកម្មសង្គម អំណាច (១៩៩៧) បានជំរុញថាវាបណ្តាលឱ្យមានអស្ថេរភាព ហើយផ្លាស់ប្តូរនូវការអនុវត្តគោល នយោបាយសម្រាប់ការត្រួតពិនិត្យយុទ្ធសាស្ត្ររបស់រដ្ឋដែលបានដាក់ចេញ ។ជាការពិតវិធីសាស្ត្របែបនេះ ត្រូវបានគេអនុវត្តតាមក្នុងករណីជាច្រើនចំពោះការប្តឹងនិងការតវ៉ាប្រឆាំងនានា ទាំងពីអ្នកតំណាងដែលបានជ្រើសរើសនៅ តាមថ្នាក់មូលដ្ឋាន និងមន្ត្រីផ្នែករដ្ឋបាល ។[៣]

## ***សំឡេងចម្រុះនៅក្នុងសវនកម្មសង្គម***

ការស្ទង់មតិនៃបទពិសោធន៍របស់សវនកម្មសង្គមនៅក្នុង Gram Panchayats ចំនួន៤១ ពីផ្នែកចំនួន៨ នៅក្នុងរដ្ឋចំនួន៧នៃប្រទេស[៤] បានជំរុញឱ្យមានការផ្លាស់ប្តូរទ្រង់ទ្រាយធំនៅក្នុងហេតុការណ៍ ចំណុចផ្តោត របៀបវារៈ សេចក្តីលម្អិតនៃនីតិវិធី ការចូលរួមរបស់ភ្នាក់ងារ ហើយនិងសមត្ថភាពក្នុងការជួយសម្រួល ។

---

[3] សម្រាប់ព័ត៌មានបន្ថែមអំពីការប្រឆាំងយ៉ាងតឹងតែងពីសំណាក់ថ្នាក់ឃុំមួយចំនួន សូមមើលពីរបាយការណ៍សារព័ត៌មាន The Hindu ដែលមានចំណងជើងថា Audit Hits a Roadblock ចេញផ្សាយថ្ងៃទី ១១ ធ្នូ ២០០៧ (បោះពុម្ពផ្សាយដោយ Dalhi) និងអត្ថបទចំណងជើងថា 'RTI Activists Stage Dharna on Social Audit' ចេញផ្សាយថ្ងៃទី ១៣ ខែធ្នូ ២០០៧ (បោះពុម្ពផ្សាយដោយ Dalhi) និងអត្ថបទ ចំណងជើងថា 'Vasundhara Raje Government Backs out of Banswara Social Audit' ចេញផ្សាយថ្ងៃទី ២៦ ខែធ្នូ ២០០៧ និងអត្ថបទរបស់ Rajasthan Patrika ចំណងជើងថា 'Sarkaar ne uthaaye NGO ki bhumika par sawaal' ចេញផ្សាយថ្ងៃទី ១២ ខែធ្នូ ២០០៧ (បោះពុម្ពផ្សាយដោយ Jaipur ) ។

[4] ការស្ទង់មតិមួយដែលត្រូវបានធ្វើឡើងដោយមានជំនួយពី SAMARTHAN (Madhya Pradesh), SAHAYI (Kerala), UNNATI (Rajasthan និង Gujarat), Sahbhagi Shikshan Kendra (Uttar Pradesh) និង PRIA (Rajasthan, Haryana និង Orissa)។

## ***ការឆ្លើយតបមកវិញរបស់រដ្ឋ***

ភាគច្រើននៃការឆ្លើយតបនៅតាមថ្នាក់ស្រុក និងតាមផ្នែកបានស្ថិតនៅជាកណ្ដាលនៃ NREGS លើកលែងតែសម្រាប់ Rajasthan ដែលបានបង្កើតបទបញ្ញត្តិដែលជាក់លាក់នៅក្នុងនីតិកម្មនានាសម្រាប់សវនកម្មសង្គម និងសកម្មភាពប្រជាពលរដ្ឋនៅតាមមូលដ្ឋានបន្សល់ទុកនូវប្រជាប្រិយភាព និងកាត់បន្ថយវិសាលភាពនៃ Madhya Pradesh ។ អំឡុងពេលដែល Rajasthan មានបទបញ្ញត្តិដែលបានចែងជាក់លាក់សម្រាប់សវនកម្មសង្គមហើយនោះ ការបញ្ជារបស់រដ្ឋាភិបាលនៅក្នុងរដ្ឋដទៃៗទៀតគឺស្ថិតក្នុងនាមជាច្បាប់គន្លឹះនៅក្នុងការធ្វើជាគំរូសម្រាប់សវនកម្មសង្គម។ នៅពេលដែលការណែនាំសម្រាប់ NREGS ត្រូវបានធ្វើឱ្យមានសុពលភាពនោះ Rajasthan នៅតែរក្សាបាននូវការលើកលែងផ្ដាច់មុខដែលការងារហត្ថកម្មរួមមានការងារសាងសង់នៃ Gram Panchayat កម្មវិធីសន្តិសុខសង្គម សេវាថែទាំសុខភាព ហើយនិងការអប់រំថ្នាក់បឋមសិក្សា កម្មវិធីពង្រីកវិស័យកសិកម្ម ប្រព័ន្ធចែកចាយជាសាធារណៈ និងសេវាទឹកសម្រាប់បរិភោគ ។ Rajasthan បានបង្កើតវេទិកាសវនកម្មសង្គមសម្រាប់គោលបំណងនៃការធ្វើសវនកម្មចំពោះការងារខាងលើ ។ កម្មវិធីបណ្ដុះបណ្ដាលមួយចំនួនត្រូវបានរៀបចំឡើងយ៉ាងទូលំទូលាយនៅក្នុង Rajasthan Gujarat nig Madhya Pradesh ដែលក៏ចង្អុលបង្ហាញពីការចូលរួមរបស់ភ្នាក់ងារជាន់ខ្ពស់ផងដែរ ។

## ***អ្នកតំណាងដែលត្រូវបានជ្រើសរើស: អ្នកជួយសម្រួលសំខាន់ៗ***

អ្នកតំណាងដែលបានជ្រើសរើសនៅក្នុងការស្ទង់មតិដែលឆ្លុះបញ្ចាំងពីមុខងារនៃ Gram Panchayat ថាជាធាតុដែលសំខាន់មួយនៅលើរបៀបវារៈ ។ គេក៏បានសង្កត់ធ្ងន់ផងដែរថា របៀបវារៈសម្រាប់សវនកម្មសង្គម Gram Sabha ក្នុងករណីដែលអាចកើតមាន គឺត្រូវបានរៀបចំដោយ Gram Panchayat ។ នៅក្នុងចំណោម Sarpan-

---

អ្នកឆ្លើយតបនៅក្នុងការស្ទង់មតិនោះរួមមាន អ្នកតំណាងដែលបានជ្រើសរើស អ្នកដឹកនាំប្រជាពលរដ្ឋ អ្នកតំណាងភ្នាក់ងារប្រជាពលរដ្ឋនៅតាមមូលដ្ឋាន មន្ត្រីអភិវឌ្ឍតាមផ្នែក មន្ត្រីដែលពាក់ព័ន្ធនៅថ្នាក់ស្រុក។ ការឆ្លើយតបសរុបចំនួន មួយរយសាមសិបពីរ (១៣២) ត្រូវបានទទួល ក្នុងនោះរួមមានការឆ្លើយតបចំនួន សែសិបមួយ (៤១) គឺទទួលបានពីអ្នកតំណាងដែល បានជ្រើសរើសមាន ២១នាក់ ជាស្ត្រី (ក្នុងនោះ៧នាក់មកពីវណ្ណៈដែលគេកំណត់ និង៣នាក់ មកពីក្រុមកុលសម្ព័ន្ធដាច់ដោយឡែកពីគ្នា) និងបុរសចំនួន២០នាក់ (ក្នុងនោះ៦នាក់មកពីវណ្ណៈដែលគេកំណត់ និង៤នាក់ មកពីក្រុមកុលសម្ព័ន្ធដោយដាច់ដោយឡែកពីគ្នា) មាន៧០នាក់ មកពីថ្នាក់ដឹកនាំប្រជាពលរដ្ឋរួមមាន ៣៥នាក់ជាស្ត្រី (ក្នុងនោះអ្នកឆ្លើយតប ១៦នាក់មកពីវណ្ណៈដែលគេកំណត់ និង៤នាក់ មកពីក្រុមកុលសម្ព័ន្ធដោយដាច់ដោយឡែកពីគ្នា) ហើយនិងបុរស ៣៥នាក់ (ក្នុងនោះអ្នកឆ្លើយតប ១២នាក់មកពីវណ្ណៈដែលគេកំណត់ និង៩នាក់ មកពីក្រុមកុលសម្ព័ន្ធដោយដាច់ដោយឡែកពីគ្នា) មាន៦នាក់មកពីភ្នាក់ងារប្រជាពលរដ្ឋតាមមូលដ្ឋាន និង១៥នាក់ មកពីក្រុមមន្ត្រីរដ្ឋាភិបាលថ្នាក់តាមផ្នែក និងថ្នាក់ស្រុក។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងនៅក្នុងរដ្ឋ Mahendragarh (Haryana), Jodhpur និង Karauli (Rajasthan), Bolangir (Orissa), Kasargod (Kerala), Sitapur (Uttar Pradesh), Sihore (Madhya Pradesh) ហើយនិង Sabarkantha (Gujarat)

ches ទាំង៤១ (ប្រធានភូមិ) ដែលត្រូវបានធ្វើបទសម្ភាសន៍ គឺមានត្រឹមតែ Sarpanches ចំនួន៣នាក់ប៉ុណ្ណោះ ដែលឆ្លើយតបថា មានការជំទាស់ទៅលើសវនកម្មសង្គម។ បញ្ហានេះបានចង្អុលប្រាប់ពីខាងដើមចំពោះកម្រិតនៃការផ្តល់សិទ្ធិដល់សហគមន៍ក្នុងការលើកជាសំណួរ។

សវនកម្មសង្គមភាគច្រើនត្រូវបានកំណត់លក្ខណៈដោយការចូលរួមយ៉ាងខ្លាំងក្លា ពីសំណាក់មន្ត្រីរដ្ឋាភិបាលនៃអង្គភាពដែលពាក់ព័ន្ធ។ នៅរាល់ករណីទាំងអស់ អ្នកតំណាងដែលត្រូវបានជ្រើសតាំងយល់ឃើញថា តួនាទីរបស់គេគឺមានភាពតឹងតែងក្នុងការគៀងគរបណ្តាសហគមន៍ តាមរយៈការជូនដំណឹងជាសាធារណៈ ហើយនិងការធ្វើឱ្យមានរបាយការណ៍សាធារណៈសម្រាប់ការត្រួតពិនិត្យ។ វាបានលើកទឹកចិត្តឱ្យមានការកត់សម្គាល់ថា សវនកម្មសង្គមជួយដល់ Sarpanches ពីសហគមន៍ SC/ST/ ជនជាតិភាគតិចឱ្យពិភាក្សាអំពីកម្មវិធីនាពេលអនាគតយ៉ាងលម្អិត និងធ្វើផែនការប្រកបដោយសេចក្តីព្រមព្រៀងគ្នាក្នុងសហគមន៍ ។

## ***ភ្នាក់ងារពលរដ្ឋ : បម្រើជាភ្នាក់ងារទំនាក់ទំនងរវាងព័ត៌មាន និងសហគមន៍***

ភ្នាក់ងារពលរដ្ឋធ្វើការដើម្បីសម្របសម្រួលឱ្យមានការទទួលបានព័ត៌មាន ប្រមូលផ្តុំសហគមន៍ ពិនិត្យពិច័យជាសាធារណៈទៅលើរបាយការណ៍ ថ្វីបើពួកគេនៅតែមានការលំបាកក្នុងការទទួលបានរបាយការណ៍សាធារណៈក៏ដោយ។ ការទទួលបានរបាយណ៍បន្ទាន់នូវសកម្មភាពដែលកើតឡើងភ្លាមៗនៅមានកម្រិត គឺវាស្រ័យទៅលើការស្វែងរករបស់សវនកម្មសង្គម។ ការឆ្លើយតបចំនួន ៦ដែលទទួលបានពីភ្នាក់ងាពលរដ្ឋផ្សេងៗបានបង្ហាញថាអន្តរាគមន៍របស់ពួកគេបានធ្វើឱ្យសហគមន៍ ទទួលបានព័ត៌មាន ហើយពិនិត្យពិច័យទៅលើវា។ ការឆ្លើយតប នេះបានបង្ហាញនូវការសហការដ៏មុតមាំមួយរវាងអ្នកតំណាងដែលបានជ្រើសរើសនៅថ្នាក់តំបន់ និងភ្នាក់ងារពលរដ្ឋដើម្បីសម្របសម្រួលដល់សវនកម្មសង្គម ថ្វីបើមន្ត្រីរដ្ឋាភិបាលជារឿយៗជំទាស់ទៅនិងសវនកម្មសង្គមក៏ដោយ។

## ***សម្លេងរបស់សហគមន៍ : ប្រសិទ្ធភាពសម្រេចបាននៃលទ្ធិប្រជាធិបតេយ្យ***

សវនកម្មសង្គមមិនមានប្រជាប្រិយភាពសម្រាប់ប្រជាពលដ្ឋនិងអ្នកដឹកនាំសហគមន៍ឡើយ ដោយសារតែពួកគេភាគច្រើនមិនបានចូលរួមក្នុងសវនកម្មសង្គម។ ការធ្វើឱ្យមានការចូលរួមរបស់អ្នកដឹកនាំប្រជាពលរដ្ឋ គឺធ្វើឡើងដោយអង្គការសង្គមស៊ីវិលនានានៅក្នុងតំបន់។ ការជំទាស់ភ្លាមៗដែលបានលើកឡើង និងកត់ត្រាទុក ហើយនៅតែមានភាពមិនស៊ីសង្វាក់ និងនៅមានកម្រិតនៅឡើយ។ ទោះជានៅមានកម្រិតក៏ដោយ ក៏អន្តរាគមន៍របស់ថ្នាក់ដឹកនាំសហគមន៍នេះ បានធ្វើឱ្យមានការឆ្លើយតបពី Panchayat ដើម្បីពង្រឹងដល់ដំណើរការសវនកម្មសង្គមនា

ពេលអនាគតដែរ។ គ្មានថ្នាក់ដឹកនាំសហគមន៍ណាម្នាក់បានផ្តល់នូវការកែតម្រូវជាក់លាក់ភ្លាមៗនៅក្នុងមុខងាររបស់ Panchayat ឡើយ។

ជាភស្តុតាងពីការឆ្លើយតប បទពិសោធន៍នៅតែមិនមានភាពស្មើគ្នាពីក្រុមដែលឆ្លើយឆ្លងព័ត៌មាន។ ឧទាហរណ៍ដូចជាក្នុងករណីនៃ Kerala គេឃើញថាថ្វីបើភ្នាក់ងារពលរដ្ឋបានប្រតិបត្តិនូវសវនកម្មសង្គមក៏ដោយ ក៏វាមិនត្រូវបានគេកត់ត្រាដោយអ្នកឆ្លើយឆ្លងព័ត៌មាន ផ្នែករដ្ឋាភិបាល អ្នកតំណាងដែលបានជ្រើសរើស និងសូម្បីតែអ្នកដឹកនាំប្រជាពលរដ្ឋនៅក្នុងតំបន់ដែរ។ ថ្វីបើសិទ្ធិទទួលបានព័ត៌មាន ត្រូវបានគេផ្តល់ឱ្យដើម្បីធ្វើឱ្យមានលក្ខណៈដូចគ្នានូវសវនកម្មនៃ NREGS ក៏ដោយ ក៏ការទទួលបានអត្ថប្រយោជន៍នៅថ្នាក់មូលដ្ឋានមានកម្រិតនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការឆ្លើយតបពីថ្នាក់ដឹកនាំប្រជាពលរដ្ឋបានសង្កត់ធ្ងន់ទៅលើនយោបាយ ដោយគូសបញ្ជាក់លើប្រសិទភាពនៃច្បាប់បបបញ្ញត្តិ ដោយធ្វើឱ្យលេចឡើងនូវច្បាប់បញ្ញត្តិ បទបញ្ជារដ្ឋាភិបាលដែលសមស្រប និងការកសាង សមត្ថភាព និងការចូលរួមពាក់ព័ន្ធរបស់ភ្នាក់ងារពលរដ្ឋ។

## ការលើកឡើងនូវបញ្ហា

*ការខ្វះខាតនូវវិធីសាស្ត្រ :*

សវនកម្មសង្គមកំពុងត្រូវបានគេប្រតិបត្តិតាមរយៈវិធីសាស្ត្រជាច្រើនដូចជា សវនកម្មលើដំណើរការការងារ ការស្ទង់មតិលើអ្នកប្រើប្រាស់សេវាចុងក្រោយពីកម្រិតនៃការពេញចិត្តរបស់ពួកគេ ការត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយការចូលរួមដោយប្រើការវាស់វែងប្រកបដោយប្រសិទ្ធភាពនៃសេវាសាធារណៈ។ ចាំបាច់ត្រូវឱ្យមានការបែងចែកភាពផ្សេងគ្នាឱ្យបានច្បាស់ លាស់។ សវនកម្មសង្គម គឺខុសគ្នាពី សណ្ឋានផ្សេងៗទៀតដោយសារតែភាពចាំបាច់របស់វា (១) មានការពាក់ព័ន្ធ យ៉ាងច្រើនពីនាយកដ្ឋានភ្នាក់ងាររាជរដ្ឋាភិបាល (២) ការធ្វើកំណែន និងការប្រើប្រាស់ថវិកា (៣)បង្ហាញនូវ ថវិកាដែលប្រើពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់សហគមន៍ដោយផ្អែកទៅលើគោលការណ៍សង្គម និងភាពស្មើគ្នា។ ដូច្នេះហើយទើបសវនកម្មសង្គមខុសពីការពិនិត្យទៅលើការវិវឌ្ឍរីកចម្រើន ឬ ប័ណ្ណរបាយការណ៍។ សវន កម្មសង្គមគឺជាដំណើរការដែលវែងឆ្ងាយស្មុគស្មាញ និងមានលក្ខណៈល្អិតល្អន់ជាង ដោយសារតែវាទាក់ទងទៅនឹងការ រៀបចំសហគមន៍ ដើម្បីឱ្យមានលទ្ធភាព ទទួលបាននូវភាពសមរម្យមួយនៃការជ្រើសរើសអ្នកទទួលផល (ការច្រានចោលអ្នកទទួលផល) ការបង្កើន ប្រាក់កម្រៃដល់សហគមន៍ ឬ ការធ្វើបទបង្ហាញអំពីព័ត៌មាននៅតំបន់ សាធារណៈតាមទ្រង់ទ្រាយដែលមានប្រជាប្រិយភាព ការជួយសម្របសម្រួលពី Gram Sabha (កិច្ចប្រជុំ សាធារណៈ) ដើម្បីពិនិត្យទៅលើទិន្នន័យ និងដំណើរការនិងការបង្កើតនូវបរិយាកាសមួយដែលអនុញ្ញាតឱ្យមាន ការសួរសំណួរនិងស្វែងរកភាពជាក់លាក់។

ភាគច្រើនស្ថាប័នសង្គមស៊ីវិលធ្វើការស្រាវជ្រាវនៅតាមផ្ទះសម្បែងរកមើលនូវចំណុចដែលចន្លោះនៅក្នុងកម្មវិធី ឬ សេវាកម្មជាក់លាក់ណាមួយ ហើយបង្ហាញវាទៅកាន់ Jan Sunvaai ដោយមិនចាំបាច់ប្រើប្រាស់របាយការណ៍សាធារណៈឡើយ ។ ថ្វីបើវាបម្រើនូវគោលបំណងដ៏ធំក្នុងការផ្តល់អំណាចដល់សហគមន៍ឱ្យមានសិទ្ធិគ្រប់គ្រងស្ថាប័នក៏ដោយក៏វាមិនត្រូវបានគេឱ្យឈ្មោះថាសវនកម្មសង្គមដែរ។ ទម្រង់បែបនេះគឺជាដើមគំនិតនៃសង្គមស៊ីវិល ហើយបានកំណត់នូវលទ្ធភាពដែលមានកម្រិត និង បន្សល់នូវភាពទទេស្អាតនៃធម្មនុញ្ញភាពរបស់រដ្ឋាភិបាល។ ទម្រង់ ដទៃទៀតដូចជា សវនកម្មសង្គមតាមរយៈវេទិកាសវនកម្មសង្គមជាមួយនឹង Sarpanch នៅពេលដែលប្រធាន មានបញ្ហាដែលទាក់ ទិនទៅនឹងលក្ខណៈដើមនៅពេលដែលតួនាទីរបស់ Sarpanch ខ្លួនឯងផ្ទាល់ស្ថិតនៅក្រោម ការត្រួតពិនិត្យ ។ វេទិកានៃសវនកម្មសង្គមក៏បានលើកជាសំណួរដែលពាក់ព័ន្ធទៅនឹងការចូលរួមរបស់ស្ត្រី និង ផ្នែកដែលគេមិនរាប់រកនិងអំពីការកំណត់ពេលវេលាដែលសមរម្យនៃសវនកម្មសង្គម ។ ក្រៅពីនេះទៀតមានទម្រង់ថ្មីៗមួយចំនួននៃសវនកម្មសង្គមដែលត្រូវបានផ្តួចផ្តើមដោយសង្គមស៊ីវិល ឬ ដោយ Panchayats តាមរយៈវេទិកាសវនកម្មសង្គមដែលមិនមានភាពឯករាជ្យ ហើយមិនមានច្បាប់ស្វ័យភាពក្នុងការធ្វើសវនកម្មសង្គម។ ប៉ុន្តែវានៅតែមានប្រជាប្រិយភាពក្នុងចំណោមភ្នាក់ងាររបស់រដ្ឋ។[៥] នៅក្នុងគោលការណ៍ណែនាំដែលបានចេញដោយក្រសួងអភិវឌ្ឍជនបទនៃរដ្ឋាភិបាលឥណ្ឌាសម្រាប់បទបញ្ញត្តិនៃ NREGS ត្រូវបានធ្វើឡើងសម្រាប់វេទិកាសវនកម្មសង្គមដែលមានប្រសិទ្ធភាព។ ប៉ុន្តែ ការយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្នត្រូវតែមានសម្រាប់ការរៀបចំការកំណត់នីតិវិធីដែលរាប់បញ្ចូល ហើយនិងការវិនិច្ឆ័យឱ្យធ្វើសវនកម្មសង្គមឱ្យកាន់តែមានទំនាក់ទំនងបន្ថែម។

*ការចូលរួមដែលរាប់បញ្ចូល*

តាមលក្ខណៈដើម ដោយសវនកម្មសង្គមមានសមាសភាពចូលរួមច្រើននោះ ហើយជួនកាល ក៏នាំឱ្យកើតមានជម្លោះផលប្រយោជន៍។ ដោយដឹងអំពីបញ្ហាធ្លាប់កើតឡើងជាច្រើនទើកភ្នាក់ងារសម្របសម្រួលបានពិនិត្យមើលការចូលរួមរបស់ភ្នាក់ងារ និងប្រជាជនដែលមានជម្លោះផលប្រយោជន៍ ហើយមានបំណង បង្កើតការយល់ស្របគ្នាមួយ។ នៅក្នុងស្ថានភាពបែបនោះ សវនកម្មសង្គមមិនអាចអនុវត្តគោលបំណងរបស់ខ្លួន។ ដូច្នេះហើយ ដើម្បីរៀបចំសវនកម្មសង្គមទៅតាមទ្រង់ទ្រាយពិតប្រាកដរបស់ខ្លួន សហគមន៍ត្រូវធ្វើការទាមទារសម្រាប់វា។ ឧទាហរណ៍ នៅក្នុង NREGS ជាការជំនួសភ្នាក់ងារសង្គមស៊ីវិល ឬ វេទិកាសវនកម្មសង្គម ក្នុងការកោះរៀបចំធ្វើសវនកម្មសង្គម ប្រសិនបើពលករខ្លួនឯងជួបជុំគ្នា ក្នុងលក្ខណៈជាសមាគមន៍ ឬ ជាក្រុមមានចំណាប់អារម្មណ៍មួយ

---

[5] នេះត្រូវបានបញ្ជាក់ពីការងារហត្ថកម្មនៃសវនកម្មសង្គមរបស់រដ្ឋភិបាលរបស់ Rajasthan ដែលមិនយកចិត្តទុកដាក់ចំពោះដំណើរជាអទិភាព និងការតំណាងដែលមានទំនោរប្រឆាំងទៅនឹងការចូលរួមដោយផ្ទាល់ ដែលនឹងជួយសម្រួលដល់ចំណាប់អារម្មណ៍របស់ភ្នាក់ងារចំពោះអព្យាក្រិត្យភាពនយោបាយ។

វានឹងនាំឱ្យមានការចូលរួមកាន់តែច្រើន និងភាពហ្មត់ចត់នៅក្នុងដំណើរការ។ នៅ Jhalawar នៃ Rajasthan ប្រសិនបើសកម្មជនសង្គមដែលកំពុងរៀបចំសវនកម្មសង្គមត្រូវបញ្ឈប់ និងបណ្តេញចេញពីភូមិ នេះគឺជាសញ្ញាថា ក្រុមដែលមានអំណាចជាង នឹងបន្តគ្រប់គ្រងដំណើរការ សេវាកម្ម និងស្ថាប័ន។ នៅក្នុងករណីបែបនោះ សវនកម្មសង្គមដែលធ្វើដោយ Panchayat នឹងមិនមានប្រសិទ្ធភាពនោះទេ ជាពិសេសខ្វះខាតប្រាក់កម្រៃ សម្រាប់ប្រជាជនក្រីក្រ និងធ្វើឱ្យខាតផលប្រយោជន៍។ ដូច្នេះ ក្រៅពីខិតខំនៅក្នុងការរៀបចំការងារហត្ថកម្ម និងការបណ្តុះបណ្តាលវេទិកាសវនកម្មសង្គម និង Sarpanches ត្រូវការឱ្យមានការខិតខំប្រឹងប្រែងកាន់តែខ្លាំងនៅក្នុងការអប់រំ និងការរៀបចំអ្នកចូលរួមគម្រោងពីដំបូង។

បញ្ហាសំខាន់ទី២ ពាក់ព័ន្ធទៅនឹងការធ្វើជាអធិបតីនៅក្នុងវេទិកាសវនកម្មសង្គម។ ក្នុងករណីភាគច្រើន ភ្នាក់ងារដែលទទួលខុសត្រូវ ដូចជាក្នុងករណីនេះ Sarpanch ធ្វើជាអធិបតីនៅក្នុងវេទិកាសវនកម្មសង្គម។ គោលការណ៍ណែនាំរបស់ NREGS បានលើកឡើងយ៉ាងច្បាស់អំពីតម្រូវការសម្រាប់ការជ្រើសរើសបុគ្គលដែលមិនមានចំណែកនៅក្នុង Panchayat ឬ ភ្នាក់ងារអនុវត្តណាមួយផ្សេងទៀតនោះទេ។ អធិបតីមិនមែនត្រឹមតែសម្របសម្រួលប៉ុណ្ណោះទេ តែថែមទាំងមានពេលវេលាគ្រប់គ្រាន់ ដើម្បីគ្រប់គ្រង ពិនិត្យមើល ទប់ស្កាត់ការមិនឯកភាពគ្នា ការខ្វែងយោបល់គ្នា និងការឈ្លោះប្រកែកគ្នា។ Sarpanches នៅក្នុងស្រុក Banswara នៃរដ្ឋ Rajasthan បានសម្រេចចិត្តធ្វើពហិការសវនកម្មសង្គម នៅក្នុង Gram Panchayat របស់ពួកគេ (សូមមើលនៅក្នុងកាសែតដែលរាយការណ៍អំពីសាសនា Hindu ស្តីពីសវនកម្មសង្គម Rajasthan បានទម្លាយរបាំងផ្លូវ "ការតវ៉ាដោយប្រើហឹង្សាដែលកើតឡើងពីតំណាងរបស់ស្ថាប័ន Panchayati Raj ដែលបានបោះឆ្នោតជ្រើសរើស នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ (ការបោះពុម្ពផ្សាយរបស់ Delhi) ស្តីពីមូលដ្ឋាននៃសវនកម្មសង្គមយ៉ាងឆាប់រហ័សដោយ "អ្នកខាងក្រៅ" ដែលស្វែងរកបានការគាំទ្រយ៉ាងឆាប់រហ័សពីរដ្ឋបាលរបស់រដ្ឋ។ ទោះបីជាយ៉ាងនេះក្តី ក្នុងករណីជនជាតិភាគតិច/តំបន់នៅដាច់ពីគេ រយៈពេលដឹកនាំ Gram Panchayat និងយន្តការដែលត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នឹងប៉ះពាល់ដល់ពួកគេយ៉ាងខ្លាំង។

បញ្ហាទី៣ ហើយជាបញ្ហាសំខាន់បំផុតក្នុងចំណោមបញ្ហាទាំងនេះ ទាក់ទងទៅនឹងវត្តមាន និងការចូលរួមរបស់សហគមន៍ ។ នៅខណៈដែលវិធីសាស្ត្រការច្បាប់និងគោលនយោបាយត្រូវបានប្រើប្រាស់ដើម្បីបង្កើតឱកាសបែបនោះ ការធានាការស្មើភាព និងការទទួលបានដោយងាយស្រួលសម្រាប់តំបន់ដែលនៅដាច់ពីគេ និងជនជាតិភាគតិចនៅ ក្នុងសហគមន៍ សមត្ថភាព ដើម្បីធានាសិទ្ធិទទួលបានសម្រាប់អ្នកដែលនៅដាច់ពីគេ។ នៅក្នុងវេទិកាសវនកម្ម សង្គម សហគមន៍ ហើយនៅក្នុងនោះ តំបន់ដែលនៅដាច់ពីគេ/ជនជាតិភាគតិចបានប្រឈមមុខនឹងការលំបាកគួរ ឱ្យកត់សម្គាល់ក្នុងការទទួលបាន ផលប្រយោជន៍ពីសវនកម្មបែបនោះ។ ក្រុមដែលគេដកសិទ្ធិមិនអាចរៀបចំកម្លាំង ប្រមូលផ្តុំបានទេ ដោយសារតែមានការបែងចែកគ្នា ហើយការពឹងផ្អែក របស់ពួកគេ

ទៅលើក្រុមគ្រប់គ្រងដែលមិនបានដឹកនាំទៅរកការផ្សារភ្ជាប់ទំនាក់ទំនងគ្នានៅក្នុងសហគមន៍ទៅនឹងការសាកសួរសំណួរ។ ក្នុងករណីបែប នោះ សវនកម្មសង្គមត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ពីនយោបាយនៃការគ្រប់គ្រង និងភ្នាក់ងារពាក់ព័ន្ធ ធ្វើឱ្យប្រសិទ្ធ ភាពធ្លាក់ចុះនៅក្នុងការបង្កើនទំនាក់ទំនងនៅក្នុងសហគមន៍នៅពេលអនាគត។ ដើម្បីជំរុញឱ្យមានគណនេយ្យភាពទាំងស្រុងវាជាការសំខាន់ណាស់ដែលត្រូវរៀបចំយន្តការស្ថាប័នដែលកាត់បន្ថយអំពើពុករលួយ និងការងារ ទៅតាមការពិនិត្យ និងវិធានការតុល្យភាព។ ការអនុវត្ត ដូចជាការប្រើការមិនបញ្ជូនជាសាច់ប្រាក់នៅក្រោម NREGS នៅ Andhra Pradesh និង Gujarat បានជួយពិនិត្យលើការបាត់បង់ដោយប្រការផ្សេងៗ។

នេះគឺដោយសារតែមិនមានភាពច្បាស់លាស់ក្នុងការបកស្រាយអ្វីដែលបានរៀបចំទៅជាការអនុវត្តទស្សនៈមិនអាចត្រូវបានគេបោះចោល។ និយាយឱ្យច្បាស់ទៅសវនកម្មសង្គមមានសក្តានុពលយ៉ាងខ្លាំងនៅក្នុងការងារ ដើម្បីពង្រឹងបណ្តាញសង្គមនៅថ្នាក់មូលដ្ឋាន។ វាបានបង្កើតឱកាសសម្រាប់ការគៀងគរឱកាសសម្រាប់ការគិតជាមុន និងយន្តការដើម្បីធានាគណនេយ្យភាព និងតម្លាភាព ដើម្បីជំរុញយុត្តិធម៌សង្គម និងពង្រឹងប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ ទោះបីជា យ៉ាងនេះក្តី គឺមានតម្រូវការបន្ទាន់មួយសម្រាប់ការងារ ដើម្បីពង្រឹងសវនកម្មសង្គម។ បទបញ្ញត្តិច្បាប់ និងគោលការណ៍ណែនាំគោលនយោបាយត្រូវការធ្វើឱ្យមានការវិវឌ្ឍ ក្រៅពីវិធានការជានិមិត្តរូប។ នៅខណៈពេលដែលមានតម្រូវការចាំបាច់សម្រាប់ការកសាងសមត្ថភាពរបស់ភ្នាក់ងារដែលពាក់ព័ន្ធនៅគ្រប់កម្រិតទាំងអស់ ហើយការងារបន្ទាន់ក៏ត្រូវបាន លើកឡើងផងដែរនៅក្នុងការពង្រឹងភាពខ្វះចន្លោះរបស់សហគមន៍។ បទពិសោធន៍នៅលើពិភពលោកជាមួយនឹងសេរីភាព សារព័ត៌មានបានផ្តល់អនុសាសន៍ថា ភ្នាក់ងារដែលជាប្រជាពលរដ្ឋមានតួនាទីយ៉ាងសំខាន់នៅក្នុងការចងក្រងឯកសារ និងតាមដានសកម្មភាព (Roberts, ២០០៦)។ ក្រុមប្រជាពលរដ្ឋបែបនោះ បានធ្វើប្រតិបត្តិការជាភ្នាក់ងាររបស់ប្រជាជន។ ទោះបីជាយ៉ាងនេះក្តី វាបានបង្ហាញថា សកម្មភាពប្រជាពលរដ្ឋផ្ទាល់ ត្រូវបានពង្រឹង ដើម្បីបង្កើតការឆ្លើយតបជាលក្ខណៈប្រព័ន្ធសម្រាប់គណនេយ្យភាព។ សកម្មភាពដែលចេញពីក្រុមប្រជាពលរដ្ឋ នៅទ្រង់ទ្រាយបែបសមាគមប្រជាពលរដ្ឋ ក្រុមជួយខ្លួនឯង ក្រុមគ្រប់គ្រងអ្នកប្រើប្រាស់ ក្រុមគ្រប់គ្រង ក្រុមបញ្ចុះបញ្ចូលតែងបានជំរុញនៅគ្រប់កម្រិតទាំងអស់ ពីកម្រិតមូលដ្ឋានទៅដល់ការបង្កើតគោលនយោបាយ។